**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤៥៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **សេនា** ជូនឯកឧត្តម **ឃឹម សិលា** ទីប្រឹក្សាអមក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ។

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៨៩ . ណ.ស

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

*ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ*

តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់អំពី ឯកឧត្តម **សយ តីរម្យ** និង ឯកឧត្តម **មាន សុភា** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ។

ដើម្បីជាការលើកទឹកចិត្តចំពោះស្នាដៃខាងលើ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលស្នើសុំព្រះរាជយោបល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ និងសូមទ្រង់ព្រះបរមរាជានុញ្ញាតប្រោសព្រះរាជទាន នូវ**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះឯកឧត្តម **សយ តីរម្យ** និង ឯកឧត្តម **មាន សុភា** ដោយព្រះទ័យអនុគ្រោះ ។

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវភក្តីភាពដ៏ស្មោះ និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៩៧ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៨០..ស.រ.

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា**

*ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ*

តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម ទូលព្រះបង្គំជាខ្ញុំសូមក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ព្រះមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់អំពី មន្ត្រីរាជការនៃក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចំនួន០៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ។

ដើម្បីជាការលើកទឹកចិត្តចំពោះស្នាដៃខាងលើ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលស្នើសុំព្រះរាជយោបល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមទ្រង់ព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ និងសូមទ្រង់ព្រះបរមរាជានុញ្ញាតប្រោសព្រះរាជទានដោយព្រះទ័យអនុគ្រោះ នូវគ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** ជូនចំពោះមន្ត្រីរាជការ ទាំង០៥រូប ដូចមានរាយនាមខាងក្រោម ៖

១-លោក **កែវ សុវត្ថិ** ទីប្រឹក្សាអមក្រសួង

២-លោក **ញ៉ៀម សាម៉ន** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន

៣-លោក **ឈា ឡាយហ៊ី** អនុប្រធាននាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម

៤-លោក **ញិល ប៊ុនធឿន** ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ

៥-លោក **សំបូរ ផូ** ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវភក្តីភាពដ៏ស្មោះ និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំជាខ្ញុំ ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៧ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**